# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧២២ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតយន្តការទប់ស្កាត់ថ្នាក់ជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៧/០០២ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីការប្រឆាំងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតយន្តការទប់ស្កាត់ថ្នាក់ជាតិមួយ សម្រាប់ចាត់ចែង រៀបចំប្រព័ន្ធទស្សនកិច្ចជាប្រចាំនៅតាមទីកន្លែងឃុំឃាំងជនដែលត្រូវបានដកហូតសិទ្ធិ សេរីភាព ដើម្បីធានាការគោរពសិទ្ធិជាមូលដ្ឋានរបស់ពួកគេសំដៅប្រឆាំងនឹង

ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម នុត សាអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍

៣-ឯកឧត្តម អ៊ិត រ៉ាឌី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ អនុប្រធាន

៤-ឯកឧត្តម ប្រុក សារឿន ប្រធានក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ សមាជិក

៥- ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ សមាជិក

៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក ហេង ហាក់ អគ្គនាយកពន្ធនាគារ សមាជិក

៧-ឯកឧត្តម ម៉ក់ សម្បត្តិ អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក

៨-លោកឧត្តមសេនីយ៍ទោ ប៊ិត គីមហុង ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សមាជិក

៩-លោកឧត្តមសេនីយ៍ទោ សារ៉ាន់ កំសត់ អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ សមាជិក

១០-លោកឧត្តមសេនីយ៍ទោ ស៊ិន សូផានី មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១១-លោក គង់ ឆាន អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

១២-លោក កែវ វិសិដ្ឋ ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៣-លោកទន្តបណ្ឌិត ប្រាក់ វណ្ណី ប្រធានការិយាល័យនីតិក្រម ក្រសួងសុខាភិបាល សមាជិក

**មាត្រា២ .-**

យន្តការទប់ស្កាត់ថ្នាក់ជាតិនេះមានភារកិច្ច និងសិទ្ធិដូចតទៅ ÷

-ត្រួតពិនិត្យជាប្រចាំនូវប្រព្រឹត្តិកម្មលើជនដែលត្រូវបានដកហូតសេរីភាពនៅតាមទីកន្លែងឃុំឃាំងនានា ដើម្បីការពារជនទាំងនោះពីអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬ ទណ្ឌកម្ម

-ផ្តល់អនុសាសន៍ជូនអាជ្ញាធរពាក់ព័ន្ធក្នុងគោលបំណងកែលំអប្រព្រឹត្តិកម្ម និងស្ថានភាពរបស់ជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព និងដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ស្របតាមស្មារតីនៃស្តង់ដាររបស់អង្គការសហប្រជាជាតិដែលពាក់ព័ន្ធ

-ធ្វើទស្សនកិច្ចត្រួតពិនិត្យកន្លែងឃុំឃាំងនានានៅទូទាំងប្រទេស

-សិទ្ធិទទួលព័ត៌មានអំពីចំនួនជនដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅតាមទីកន្លែងឃុំឃាំង ស្ថានភាព នៃការឃុំឃាំង និងអំពីប្រព្រឹត្តិកម្មលើជនទាំងនោះផង

-សិទ្ធិចេញចូលគ្រប់កន្លែងឃុំឃាំង ទីតាំង និងរចនាសម្ព័ន្ធនៃកន្លែងឃុំឃាំង

-ធ្វើជាសេនាធិការឱ្យអនុគណៈកម្មការទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម នៃគណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម របស់អង្គការសហប្រជាជាតិ

-លើកសំណើ និងធ្វើសេចក្តីសង្កេតលើច្បាប់ដែលមានស្រាប់ ឬសេចក្តីព្រាងច្បាប់នានា

-ទទួល និងធ្វើទំនាក់ទំនងជាមួយអនុគណៈកម្មាធិការទប់ស្កាត់ ដើម្បីផ្តល់លទ្ធភាពឱ្យអនុគណៈកម្មាធិការនេះអាចបំពេញអាណត្តិការងាររបស់ខ្លួនបានស្របតាមមាត្រា ២០ នៃពិធីសារ ។

**មាត្រា៣ .-**

ការប្រើប្រាស់អំណាចរបស់យន្តការទប់ស្កាត់ថ្នាក់ជាតិនេះ មិនត្រូវឱ្យប៉ះពាល់ដល់បុព្វសិទ្ធិដែលច្បាប់ប្រគល់ឱ្យអំណាចតុលាការឡើយ ។

**មាត្រា៤ .-**

យន្តការទប់ស្កាត់ថ្នាក់ជាតិ មានឯករាជ្យភាពមុខងារ ដោយមិនទទួលយកការបញ្ជាណែនាំពីអាជ្ញាធរថ្នាក់ណាមួយឡើយក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

**មាត្រា៥ .-**

ប្រធានយន្តការទប់ស្កាត់ថ្នាក់ជាតិ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយដោយធ្វើការជ្រើសរើសយកមន្ត្រី ដែលមានក្របខ័ណ្ឌស្រាប់របស់ក្រសួង ស្ថាប័នដែលមានសមាសភាពនៅក្នុងយន្តការទប់ស្កាត់ថ្នាក់ជាតិនេះ ។លេខាធិការដ្ឋាននេះមានភារកិច្ចសរុបរបាយការណ៍របស់យន្តការទប់ស្កាត់ថ្នាក់ជាតិជូនអនុគណៈកម្មការទប់ស្កាត់របស់អង្គការសហប្រជាជាតិ ។

**មាត្រា៦ .-**

ការចាត់ចែងសមាសភាព និងការកំណត់ភារកិច្ចរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៧ .-**

ធនធានចាំបាច់សម្រាប់ដំណើរការយន្តការនេះ ជាបន្ទុករបស់ថវិកាជាតិ ក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ និងធនធានដែលជាអំណោយរបស់អង្គការជាតិ និងអន្តរជាតិ ។

**មាត្រា៨ .-**

យន្តការទប់ស្កាត់ថ្នាក់ជាតិ និងលេខាធិការដ្ឋានរបស់យន្តការថ្នាក់ជាតិនេះ ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈចំពោះហេតុការណ៍ ទង្វើ ឬ ព័ត៌មានដែលខ្លួនបានដឹងក្នុងពេលបំពេញមុខនាទី លើកលែងតែហេតុការណ៍ ទង្វើ ឬ ព័ត៌មានដែលចាំបាច់សម្រាប់ធ្វើរបាយការណ៍ អនុសាសន៍និងមតិដែលត្រូវបញ្ចេញ ដោយអនុលោមតាមអនុសញ្ញា និងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការប្រឆាំងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ។

**មាត្រា៩ .-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ ដែលមានបំណងចង់ឱ្យមានការគោរពសិទ្ធិជាមូលដ្ឋាន អាចជូនដំណឹងទៅយន្តការទប់ស្កាត់ថ្នាក់ជាតិអំពីទីកន្លែង អំពីហេតុការណ៍ផ្សេងៗ ឬ អំពីស្ថានភាព នៃការឃុំឃាំងជនដែលត្រូវបានដកហូត

សិទ្ធិសេរីភាព បើយល់ឃើញថាចាំបាច់ ។

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារបស់រាជរដ្ឋាភិបាល និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី...០៧...ខែ...សីហា...ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ